**ក្រសួងផែនការ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុ
## អង្គប្រជុំ គណៈកម្មាធិការសម្របសម្រួលស្ថិតិ
## លើកទី ២

ឆ្នាំ ពីរពាន់ប្រាំពីរ ខែ កក្កដា ថ្ងៃទី ម្ភៃប្រាំពីរ វេលាម៉ោង ប្រាំបីនិងសាមសិបនាទី នៅសាលប្រជុំវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការមានបើកអង្គប្រជុំ គណៈកម្មាធិការសម្របសម្រួលស្ថិតិ ក្រោមអធិបតីភាពឯកឧត្តម សន ស៊ីថន អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ជាប្រធានគណៈកម្មាធិការ ដែលមានសមាសភាពចូលរួមដូចខាងក្រោម :

| | |
|---|---|
| ១- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | តំណាងចូលរួម |
| ២- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៣- ក្រសួង អភិវឌ្ឍន៍ជនបទ | តំណាងចូលរួម |
| ៤- ក្រសួង មហាផ្ទៃ | តំណាងចូលរួម |
| ៥- ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧- ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | តំណាងចូលរួម |
| ៩- ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១០- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ១១- ក្រសួងព័ត៌មាន | សមាជិក |
| ១២- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៣- ក្រសួង ធនធានទឹក និងឧតុនិយម | តំណាងចូលរួម |
| ១៤- ក្រសួង យុត្តិធម៌ | សមាជិក |
| ១៥- ទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ១៦- ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ | តំណាងចូលរួម |
| ១៧- នាយកដ្ឋាន ពន្ធដារ | សមាជិក |

១៨- ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១៩- ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល តំណាងចូលរួម

២០- ក្រសួង កិច្ចការនារី តំណាងចូលរួម

២១- ក្រសួង ទេសចរណ៍ តំណាងចូលរួម

២២- ធនាគារជាតិ នៃកម្ពុជា តំណាងចូលរួម

២៣- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តំណាងចូលរួម

អវត្តមាន: ក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួង សុខាភិបាល អាកាសចរណ៍ស៊ីវិល ក្រសួងការពារជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងធម្មការ និងសាសនា ក្រសួងពាណិជ្ជកម្ម ។

កម្មវិធីនៃអង្គប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិលើកទី២ រួមមាន :

-មតិស្វាគមន៍របស់ប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ

-របាយការណ៍ស្តីពីសកម្មភាពអនុវត្តគម្រោង កិច្ចអភិវឌ្ឍន៍សមត្ថភាព របស់ប្រព័ន្ធស្ថិតិជាតិ

-ការប្រមូលព័ត៌មានពីក្រសួង ស្ថាប័ន ដើម្បីរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ។

-បញ្ហាផ្សេង ៗ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិបានថ្លែងសន្ទរកថាស្វាគមន៍អង្គប្រជុំដោយបានលើកឡើងនូវទីតាំងរបស់ប្រព័ន្ធស្ថិតិជាតិកម្ពុជានៅក្នុងប្រព័ន្ធស្ថិតិ សកលលោក និងបានលើកឡើងនូវសមត្ថភាព បទពិសោធន៍បណ្តាប្រទេសនានា ដែលបានអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជឿនលឿនដូចជាស្ថានប័នស្ថិតិ អូស្ត្រាលី កាណាដា ។ អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិក៏បានលើកឡើងថាអង្គប្រជុំ នេះក៏ជាអង្គប្រជុំមួយយ៉ាងសំខាន់ក្នុងការពង្រីកប្រព័ន្ធស្ថិតិជាតិកម្ពុជា ដោយសំណូមពរឱ្យអស់លោក លោកស្រី ទាំងអស់ដែលបានចូលរួមប្រជុំនាពេលនេះសូមពិចារណា តើត្រូវយកសកម្មភាពស្ថិតិណាដាក់ក្នុងសេចក្តីព្រាងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងព្រោះថាបើបានដាក់ហើយ ត្រូវតែអនុវត្តឱ្យបាន ។ តមកឯកឧត្តម បានអញ្ជើញលោក ប៉ាង កាណុល មន្ត្រីគ្រប់គ្រងគំរោងអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិ ដែលឧបត្ថម្ភដោយ UNDP ធ្វើបទបង្ហាញស្តីពីសកម្មភាពរបស់គំរោង និងទិសដៅតទៅខាងមុខដែលពាក់ព័ន្ធទៅនឹងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការ ដែលបានចាត់តាំង ដែលជាការងាររបស់ បណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ។

បន្ទាប់ពីលោក ប៉ាង កាណុល បានធ្វើបទបង្ហាញស្តីពីសកម្មភាពក្នុងការពង្រឹងសមត្ថភាព របស់ប្រព័ន្ធស្ថិតិជាតិ និងទិសដៅដែលត្រូវបង្កើតអនុក្រឹត្យជាច្រើន ក្រោយពីច្បាប់ស្តីពីស្ថិតិចូលជាធរមានរួចមក ដែលក្នុងនោះក៏ត្រូវបង្កើតអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ដែលជាភារកិច្ច តម្រូវឱ្យក្រសួងនានាធ្វើការចងក្រងស្ថិតិតាមវិស័យរបស់ខ្លួន ។

នៅក្នុងកម្មវិធីប្រមូលព័ត៌មានស្ថិតិ ពីក្រសួងស្ថាប័ន ឯកឧត្តមប្រធានអង្គប្រជុំបានស្នើសុំមតិពីក្រសួងស្ថាប័ន :

- មតិតំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល :

ក្នុងសេចក្តីព្រាងអនុក្រឹត្យឃើញថាមានខ្លឹមសារតិចតួច គឺសុំបន្ថែម

- ស្ថិតិការចុះបញ្ជីរោងចក្រ ប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ
- ស្ថិតិការចុះបញ្ជីសិប្បកម្ម ប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ
- ស្ថិតិការចុះបញ្ជីទឹកស្អាត ប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ
- ស្ថិតិការចុះបញ្ជីថាមពលអគ្គីសនី ប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ

សំណួរ : តើស្រង់ស្ថិតិ កំលាំងពលកម្មដែរ ឬ ទេ ?

ចម្លើយ : លោក Zia Abbasi បានជួយបំភ្លឺថា កំលាំងពលកម្ម មិនបានស្រង់ស្ថិតិទេ , ព្រោះសុំទុកឱ្យក្រសួងការងារ និងបណ្តុះបណ្តាវិជ្ជាជីវៈជាអ្នកចងក្រង ។

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ បានលើកឡើងពីប្រព័ន្ធស្ថិតិជាតិរបស់ប្រទេសក្នុងសកលលោក រួមមានប្រព័ន្ធប្រមូលផ្តុំ និងប្រព័ន្ធមិនប្រមូលផ្តុំដែលត្រូវមានយន្តការសម្របសម្រួល ហើយអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង គឺជួយឱ្យយន្តការសម្របសម្រួលដំណើរការបានរលូន និងច្បាស់លាស់ ។ ឯកឧត្តមសំណូមពរឱ្យគ្រប់ក្រសួងស្ថាប័នពិនិត្យ និងមានយោបល់លើសេចក្តីព្រាង ។

- មតិក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ : ផលិតផលដំណាំ , ខាងវិទ្យាស្ថានជាតិស្ថិតិបានយកមកធ្វើគណនេយ្យជាតិ តើក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរបញ្ចូលក្នុងអនុក្រឹត្យដែលរឺទេ ? ជាគំនិតសុំបញ្ចូលក្នុងអនុក្រឹត្យ ។

ចម្លើយ : វិទ្យាស្ថានជាតិស្ថិតិ យើងយកតែតួលេខមកគិតតំលៃបន្ថែម (GVA) សំរាប់គណនាគណនេយ្យជាតិទេ ។ ដូច្នេះចំពោះស្ថិតិ ផលិតផលកសិកម្មសុំបញ្ចូលបាន ។

- មតិក្រសួងអប់រំ យុវជន និងកីឡា :

ចំណុចមួយសុំសួរ "ការសិក្សាមិនផ្លូវការ " បើនិយាយពីភាសាអង់គ្លេស នោះប្រហែលជា " ស្ថិតិក្រៅប្រព័ន្ធ" ។

ចម្លើយ : ត្រឹមត្រូវហើយសុំឯកភាព ។

-មតិក្រសួងសង្គមកិច្ច អតីតយុទ្ធជន នីតិសម្បទា :

សុំដាក់ពាក្យក្រសួងឱ្យពេញគឺថែម " យុវនីតិសម្បទា" ចំពោះស្ថិតិ ជនពិការ សុំពិភាក្សាគ្នាជាមួយក្រសួងសុខាភិបាល ។

-មតិក្រសួងព័ត៌មាន:

សុំដាក់ស្ថិតិប្រព័ន្ធផ្សព្វផ្សាយអប់រំប្រចាំឆ្នាំ

- មតិក្រសួងទេសចរណ៍:

សុំជូរពាក្យពេចន៍

-ស្ថិតិទេសចរជាតិ និងអន្តរជាតិ

-ស្ថិតិចំណូលចំណាយទេសចរប្រចាំឆ្នាំ

-ស្ថិតិសេវាកម្មទេសចរប្រចាំឆ្នាំ

ដោយពិនិត្យឃើញថាកិច្ចពិភាក្សាមានច្រើនហើយពេលវេលាក៏អស់ ម្យ៉ាងទៀតក៏ចង់ឱ្យអស់លោក លោកស្រីដែលចូលរួមប្រជុំនាពេលនេះបានទៅពិគ្រោះ និងឆ្លងថ្នាក់ដឹកនាំក្រសួងស្ថាប័នផងនោះ ឯកឧត្តមប្រធានអង្គប្រជុំក៏សំណូមពរអង្គប្រជុំយកការងារទៅពិភាក្សាតាមក្រសួងរៀងខ្លួន ហើយពេលបានសំរេចពីថ្នាក់ដឹកនាំ ក្នុងការបន្ថែមឬបន្ថយនូវចំណុចណានោះ សូមផ្ញើមកវិទ្យាស្ថានជាតិស្ថិតិ អោយបានមុខតំណាច់ខែ សីហា ឆ្នាំ ២០០៧ ជាកំណត់ ។

ចំពោះសមាជិកក្រសួងស្ថាប័នដែលអវត្តមាន ក៏សំណូមពរឱ្យរៀបចំធ្វើដូចគ្នាអញ្ចឹងដែរ ។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១១:៤០នាទី ថ្ងៃ ខែ ឆ្នាំដដែល ។

បានឃើញ និងឯកភាព

ប្រធានអង្គប្រជុំ

សន ស៊ីថន

លេខាកត់ត្រា

ទី ហៀង